COMMUNITY LEGAL SERVICES · Est. 1966 · CLS · OF PHILADELPHIA

# ជំនួយផ្នែកវេជ្ជសាស្ត្រសម្រាប់ជនអន្តោប្រវេសន៍នឹងមានការផ្លាស់ប្តូរ ចាប់ពីថ្ងៃទី 1 ខែតុលា ឆ្នាំ 2026 តទៅ

**មនុស្សជាច្រើននឹងនៅតែមានសិទ្ធិទទួលបានជំនួយផ្នែកវេជ្ជសាស្ត្រ (Medical Assistance ឬហៅកាត់ថា MA) នៅក្នុងខែតុលា។ សូមចាត់វិធានការឥឡូវនេះ ដើម្បីបង្ហាញថាអ្នកមានសិទ្ធិគ្រប់គ្រាន់!**

1. **ប្រសិនបើអ្នកមានកាតបៃតង សូមប្រាកដថាការិយាល័យជំនួយប្រចាំខោនធី (County Assistance Office ឬហៅកាត់ថា CAO) មានច្បាប់ចម្លងរបស់វា។** ពួកគេប្រហែលជាមិនដឹងថាអ្នកមានសិទ្ធិឡើយ ហើយអាចនឹងកាត់ផ្តាច់អត្ថប្រយោជន៍របស់អ្នកនៅក្នុងខែតុលា ឆ្នាំ 2026។

2. **សូមប្រាកដថាការិយាល័យជំនួយប្រចាំខោនធី (CAO) ដឹងពីអាយុរបស់កុមារ និងអំពីការមានផ្ទៃពោះណាមួយនៅក្នុងគ្រួសាររបស់អ្នក។** បទប្បញ្ញត្តិទាំងនេះមិនមានការផ្លាស់ប្តូរឡើយសម្រាប់កុមារអាយុក្រោម 21 ឆ្នាំ និងមនុស្សពេញវ័យដែលកំពុងមានផ្ទៃពោះ ឬទើបតែសម្រាលកូនរួចក្នុងរយៈពេល 12 ខែ។ អ្នកដែលមានសិទ្ធិទទួលបានជំនួយផ្នែកវេជ្ជសាស្ត្រ (MA) នៅពេលបច្ចុប្បន្ន នឹងនៅតែបន្តមានសិទ្ធិក្នុងខែតុលា ឆ្នាំ 2026។

3. **សូមប្រុងប្រយ័ត្ន និងរង់ចាំមើលលិខិតពី CAO ដែលសាកសួរអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នក។** CAO នឹងចាប់ផ្តើមផ្ញើលិខិតទាំងនេះតាមប្រៃសណីយ៍នៅក្នុងខែមិថុនា ឆ្នាំ 2026។ ប្រសិនបើអ្នកទទួលបាន MA សម្រាប់ខ្លួនអ្នក ហើយអ្នកមានស្ថានភាពអន្តោប្រវេសន៍ដែលមានសិទ្ធិគ្រប់គ្រាន់ អ្នកត្រូវតែឆ្លើយតបទៅនឹងលិខិតទាំងនេះ ដើម្បីរក្សាជំនួយផ្នែកវេជ្ជសាស្ត្ររបស់អ្នកក្នុងខែតុលា ឆ្នាំ 2026។

****សូមចងចាំ****

ប្រសិនបើអ្នកមិនទទួលបាន MA សម្រាប់ខ្លួនអ្នក ឬប្រសិនបើអ្នកទទួលបាន MA សម្រាប់តែការព្យាបាលស្ថានភាពអាសន្នផ្នែកវេជ្ជសាស្ត្រប៉ុណ្ណោះ CAO មិនគួរដាច់ខាតសាកសួរអ្នកអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកឡើយ ហើយអ្នកក៏មិនចាំបាច់ប្រាប់ពួកគេអ្វីទាំងអស់អំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកដែរ។

4. **សូមដាក់ពាក្យប្តឹងតវ៉ាភ្លាមៗ ប្រសិនបើទទួលបានសេចក្តីជូនដំណឹងអំពីការកាត់ផ្តាច់ជំនួយផ្នែកវេជ្ជសាស្ត្រ។** នៅពេលដែល CAO មានកំហុសឆ្គង ការដាក់ពាក្យប្តឹងតវ៉ាគឺជាវិធីដ៏ល្អបំផុតដើម្បីដោះស្រាយបញ្ហានោះ។

5. **សូមស្វែងរកជំនួយពីអ្នកគាំពារ ប្រសិនបើអ្នកត្រូវការ។** បទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបាន MA សម្រាប់ជនអន្តោប្រវេសន៍គឺមានភាពស្មុគស្មាញ ហើយ CAO តែងតែធ្វើខុសជារឿយៗ។ អ្នកគាំពារអាចនឹងជួយអ្នកបាន។ អ្នកអាចមកកាន់សេវាកម្មច្បាប់សហគមន៍ (Community Legal Services - CLS) ដើម្បីសុំជំនួយ ប្រសិនបើអ្នករស់នៅក្នុងទីក្រុង Philadelphia។ សម្រាប់អ្នកនៅក្រៅទីក្រុង Philadelphia សូមស្វែងរកកម្មវិធីជំនួយផ្នែកច្បាប់ក្នុងតំបន់របស់អ្នកតាមរយៈ៖ https://palegalaid.net/find-legal-help.

**ត្រូវការជំនួយផ្លូវច្បាប់? សូមទៅកាន់ផ្នែកទទួលព័ត៌មានរបស់ CLS សម្រាប់អត្ថប្រយោជន៍សាធារណៈ។**

- ទុកសារសំឡេងមកកាន់យើងខ្ញុំ (215-227-2400)៖ នៅថ្ងៃចន្ទ និងថ្ងៃពុធ វេលាម៉ោង 9:00 ព្រឹក ដល់ 12:00 ថ្ងៃត្រង់។
- អញ្ជើញមកកាន់ការិយាល័យរបស់យើងខ្ញុំផ្ទាល់ (1410 W Erie Ave)៖ នៅថ្ងៃអង្គារ និងថ្ងៃព្រហស្បតិ៍ វេលាម៉ោង 9:00 ព្រឹក ដល់ 12:00 ថ្ងៃត្រង់។

**ជនអន្តោប្រវេសន៍មួយចំនួននឹងមិនមានសិទ្ធិទទួលបានឡើយនៅក្នុងខែតុលា។ សូមត្រៀមលក្ខណៈជាមុនចាប់ពីពេលនេះតទៅ ក្រែងលោអ្នកត្រូវបាត់បង់ជំនួយផ្នែកវេជ្ជសាស្ត្រនៅក្នុងខែតុលា!**

# <u>សូមប្រើប្រាស់ MA របស់អ្នក ប្រសិនបើអ្នកមានវា</u>

ជនអន្តោប្រវេសន៍មួយចំនួនដែលមានសិទ្ធិទទួលបាន MA មុនថ្ងៃទី 1 ខែតុលា ឆ្នាំ 2026 នឹងលែងមានសិទ្ធិទទួលបាន MA ទៀតហើយ បន្ទាប់ពីថ្ងៃទី 1 ខែតុលា ឆ្នាំ 2026។ ប្រសិនបើអ្នកមាន MA នៅពេលបច្ចុប្បន្ន នេះជាកិច្ចការមួយចំនួនដែលអ្នកអាចធ្វើបានដើម្បីការពារខ្លួនអ្នក ក្នុងករណីដែលអ្នកបាត់បង់ MA ក្នុងខែតុលា។

1. **ទទួលយកការថែទាំវេជ្ជសាស្ត្រ មុនថ្ងៃទី 1 ខែតុលា ឆ្នាំ 2026។** កាលណាអ្នកប្រើប្រាស់ MA របស់អ្នកបានកាន់តែច្រើន មុនថ្ងៃទី 1 ខែតុលា ឆ្នាំ 2026 គឺកាន់ តែប្រសើរ។

2. **បំពេញវេជ្ជបញ្ជាទិញថ្នាំឡើងវិញ** មុនថ្ងៃទី 1 ខែតុលា ឆ្នាំ 2026។

3. **ទិញឧបករណ៍វេជ្ជសាស្ត្រ** (ដូចជា រទេះរុញ ឬឈើច្រត់សម្រាប់ជួយដើរ, ឈើច្រត់ទប់, សម្ភារៈសម្រាប់ជំងឺទឹកនោមផ្អែម និងស្ថានភាពជំងឺផ្សេងៗទៀត) មុនថ្ងៃទី 1 ខែតុលា ឆ្នាំ 2026។

4. **ស្វែងរកគ្លីនិកសុខភាពដែលមិនគិតថ្លៃ ឬមានតម្លៃទាប ដែលអ្នកអាចប្រើប្រាស់បាន ប្រសិនបើអ្នកបាត់បង់ MA។** ស្វែងរកតាមរយៈតំណភ្ជាប់នេះ ឬស្កេនកូដ QR តាមទូរសព្ទរបស់អ្នក៖ <u>www.phila.gov/documents/list-of-federally-qualified-health-centers/</u>.

នៅពេលដែលបទប្បញ្ញត្តិទាំងនេះផ្លាស់ប្តូរ យើងនឹងស្វែងយល់បន្ថែម ហើយនឹងធ្វើបច្ចុប្បន្នភាពលើគេហទំព័ររបស់យើង៖ **<u>clsphila.org</u>**។

**ត្រូវការជំនួយផ្លូវច្បាប់? សូមទៅកាន់ផ្នែកទទួលព័ត៌មានរបស់ CLS សម្រាប់អត្ថប្រយោជន៍សាធារណៈ។**

- ទុកសារសំឡេងមកកាន់យើងខ្ញុំ (215-227-2400)៖ នៅថ្ងៃចន្ទ និងថ្ងៃពុធ វេលាម៉ោង 9:00 ព្រឹក ដល់ 12:00 ថ្ងៃត្រង់។
- អញ្ជើញមកកាន់ការិយាល័យរបស់យើងខ្ញុំផ្ទាល់ (1410 W Erie Ave)៖ នៅថ្ងៃអង្គារ និងថ្ងៃព្រហស្បតិ៍ វេលាម៉ោង 9:00 ព្រឹក ដល់ 12:00 ថ្ងៃត្រង់។